ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ នៅលើផ្លូវជាតិលេខ១
# ចំណុចភូមិថ្នល់ជាតិ សង្កាត់ច្រកម្ទេស ក្រុងបាវិត ខេត្តស្វាយរៀង
# ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីរន្ធត់ និងសោកស្តាយយ៉ាងក្រៃលែង នៅពេលបានទទួលដំណឹងថា មានឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍រថយន្តដឹកកម្មករដូចគ្នាបុកគ្នាពីក្រោយ កាលពីវេលាម៉ោង១៧និង១០នាទីល្ងាច ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ ស្ថិតតាមផ្លូវជាតិលេខ១ នៅចន្លោះគីឡូម៉ែត្រលេខ ១៤៧ និង១៤៨ ចំណុចភូមិថ្នល់ជាតិ សង្កាត់ច្រកម្ទេស ក្រុងបាវិត ខេត្តស្វាយរៀង ដែលបានបណ្តាលកម្មករចំនួន១២នាក់ បានរងរបួស ក្នុងនោះរបួសស្រាលចំនួន៨នាក់ និងរបួសធ្ងន់ចំនួន៤នាក់។ អ្នករងរបួសទាំងនេះបានទទួលការជួយសង្គ្រោះ ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដោយយកចិត្តទុកដាក់បំផុត។ គិតត្រឹមម៉ោង១០ និង៣០នាទីព្រឹក ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ នេះ អ្នករងរបួសទាំងអស់បានវិលចូលមកធ្វើការជាធម្មតាវិញ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបន្តជួយដោះស្រាយទុក្ខលំបាករបស់បងប្អូនកម្មការិនី និងក្រុមគ្រួសារទៅតាមគោលរបបសន្តិសុខសង្គម របស់បេឡាជាតិរបបសន្តិសុខសង្គម។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០១៦

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩